**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០២០/០៦ របក.កកចនយ**

**របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ធ្នូ ឆ្នាំ ២០០៦របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាបនិងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ ធ្នូ ឆ្នាំ ២០០៦ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្រប សម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយ សម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ក. <u>ការងាររដ្ឋបាល</u>

- ផ្ញើលិខិតជូនក្រសួង ស្ថាប័នពាក់ព័ន្ធ សុំរបាយការណ៍ប្រចាំឆ្នាំ ២០០៦ ស្តីពីការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍ស្តីពីការទស្សនាស្ថាប័នវិស័យយុត្តិធម៌នៃរដ្ឋញូសៅស្សវ៉េល (អូស្ត្រាលី) របស់ ឯកឧត្តមប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជូនសហ ប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ខ. <u>ការងារអនុវត្តកម្មវិធីកំណែទម្រង់</u>

- ចុះពិនិត្យមើលតុលាការគំរូខេត្តកណ្តាល នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៦ ក្រោមអធិបតីភាពរបស់ ឯកឧត្តម ស៊ុំ ម៉ានិត ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍

- សិក្សារៀបចំស្តង់ដា សម្រាប់តុលាការគំរូកម្ពុជា
- រៀបចំរបាយការណ៍ស្តីពីការចុះជួបអង្គការសង្គមស៊ីវិល និងព្រាងគោលនយោបាយស្តីពីការបង្កើត ប្រព័ន្ធទិន្នន័យ ស្តីពីកម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្សនៅកំរិតសហគមន៍ (គម្រោង សិទ្ធិទទួលបាន យុត្តិធម៌នៅកម្ពុជា លេខ ១.១.១)
- លើកគម្រោងធ្វើសិក្ខាសាលាស្តីពីការបង្កើតប្រព័ន្ធទិន្នន័យអំពីកម្មវិធីលើកកំពស់ការយល់ដឹងសិទ្ធិ មនុស្សនៅកម្ពុជា

គ. <u>ផ្សេងៗ</u>

- ជួបទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធមួយចំនួនជុំវិញធ្វើរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ បំណាច់ឆ្នាំ ២០០៦ (ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងបរិស្ថាន ។ល។ )

២- សន្និដ្ឋាន

ក្នុងខែ ធ្នូ ឆ្នាំ ២០០៦ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គ ភាពប្រតិបត្តិ បានបំពេញការងារយ៉ាងសកម្មក្នុងការចាប់ផ្តើមគម្រោងថ្មីៗមួយចំនួនមានជាអាទិ៍ ៖

- គម្រោងកម្មវិធីលើកកំពស់ការយល់ដឹងសិទ្ធិនៅកំរិតសហគមន៍ (គម្រោងលេខ ១.១.១ A2J)
- គម្រោងតុលាការគំរូ ។

**៣- ទិសដៅអនុវត្តក្នុងខែបន្ត**

- អនុវត្តគម្រោងថ្មីជាបន្ត
- រៀបចំរបាយការណ៍សម្រាប់ឆ្នាំ ២០០៦
- បញ្ចប់សៀវភៅមគ្គុទេសសម្រាប់វិស័យច្បាប់ និងតុលាការ
- បញ្ចប់ឯកសារពាក់ព័ន្ធ និងលក្ខណៈវិនិច្ឆ័យជាតិសម្រាប់តុលាការគំរូ
- ពិនិត្យផែនការណ៍ការងារប្រចាំឆ្នាំ សម្រាប់គម្រោង A2J ជាមួយ UNDP

- បន្តការងារបញ្ចប់របាយការណ៍របស់ IRL ស្តីពីការស្ទង់មតិលើជំនួយផ្នែកច្បាប់ជាមួយ EWMI
- បន្តការងារជ្រើសរើស Contractor សម្រាប់ CCJAP III ជាមួយ AusAid
- ពិភាក្សាជាមួយ DANIDA អំពីជំនួយរបស់រដ្ឋាភិបាល Denmark ចំពោះកំណែទម្រង់ច្បាប់ និងតុលាការ ។

*រាជធានី ភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**ហ៊្សីង សុគុល**

**ស៊ុយ ម៉ុងលាង**